ដុនបូស្កូ ខេត្តព្រះសីហនុ
ក្រុម ១៣ មណ្ឌល ០៥
សង្កាត់ ០៤ ខណ្ឌមិត្តភាព
ផ្លូវ អូប្រាំ

# ខែ មីថុនា ឆ្នាំ ២០១០

# ព្រឹត្តិបត្រសាឡេស៊ាន

# Khmer Salesian Bulletin





## Don Bosco SHV

## អភិបាលថ្មីនៅភូមិភាគភ្នំពេញ

## សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសប្បុរសជន

# សាលាបច្ចេកទេស ដុន បូស្កូ ខេត្តព្រះសីហនុ

DB

មិថុនា ២០១០

## មាតិការ




៣ លិខិតអបអរសាទរពីលោកឪពុក ចន វីស័រ ក្នុងឱកាស បុណ្យកត្តញ្ញូ

៥ - ៦ ខ្ញុំចង់ចាំដំណើរទស្សនកិច្ច របស់អ្នកម្តាយ អ៊ីវ៉ូនេ មកកាន់ប្រទេសកម្ពុជា

១១ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសប្បុរសជន

១០ អូលីវីយេ ផ្ទិតហាស្លេ ជាអភិបាលថ្មីនៅភូមិភាគភ្នំពេញ

៧ - ៨ ដំណើរទស្សនកិច្ចដុន បូស្កូប៉ោយប៉ែត


www.donboscosihanoukville.or


ក្រុមអ្នករៀបរៀងព្រឹត្តិប័ត្រសាឡេស៊ាន

លោកពុក សំណាង និពន្ធនាយក

លោកគ្រូ អ៊ុច សំបូរ និពន្ធនាយករង - រចនា - គំនូរព្រាង

និស្សិត ឡេង ឈុន រចនា - គំនូរព្រាង

លោកគ្រូ ឈិន សៀង គេហទំព័រ





# លិខិតអបអរសាទរពីលោកឪពុក ចន វីស៊រ ក្នុងឱកាស បុណ្យកត្តញ្ញូ



សូមជំរាបជូនមកដល់ សប្បុរសជន មិត្ត លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់ជាទីគោរពរាប់អាន។ នៅថ្ងៃទី២៤ ខែមិថុនា ខាងមុខនេះសាលាបច្ចេកទេសដុនបូស្កូខេត្តព្រះសីហនុ នឹងប្រារព្ធពិធីបុណ្យកត្តញ្ញូ។ ឆ្នាំសិក្សានៅក្នុងឆ្នាំនេះនឹងត្រូវបានបញ្ចប់នៅពេលឆាប់ៗ និងមានសិស្សចំនួនជាង ២០០ នាក់ បញ្ចប់ពីសាលាដែលបានទទួលការអប់រំរយៈពេលពីរឆ្នាំ ដើម្បីចូលទៅបំរើការងារ នៅក្នុងសង្គម។

វាពិតជាសាកសម ដែលយើងប្រារព្ធធ្វើពិធីនេះឡើងដើម្បីថ្លែងអំណរគុណជូនចំពោះអ្នកដែលបានបរិច្ចាកជួយដល់សាលាប្រកបដោយភាពជោគជ័យក្នុងឆ្នាំ២០០៩-២០១០។ ខ្ញុំតែងតែនិយាយប្រាប់សិស្សរបស់ខ្ញុំ៥០៨នាក់ថា សាលាដុនបូស្កូខេត្តព្រះសីហនុមានបីក្រុម:

ក្រុមទីមួយគឺជាសិស្សដែលមកពីតំបន់ក្រីក្រប៉ុន្តែពួកគេជំនះរាល់ឧបសគ្គដើម្បីការរៀនសូត្រហើសាលាបច្ចេកទេសដុនបូស្កូក៏បានផ្តល់ឱកាសដ៏ល្អមួយនៅក្នុងជីវិតរបស់ពួកគេ។

ក្រុមទីពីរគឺជាគ្រូបង្ហាត់បង្រៀនដែលឈរពីខាក្រោយសិស្សដើម្បីបង្រៀននិងជួយសំរេចនូវតំរូវការរបស់ពួកគេអោយទទួលបានជោគជ័យ។

ក្រុមទីបីគឺជាអ្នកជំនួយដែលបានជួយឧបត្ថម្ភដល់សាលាធ្វើអោយសាលាមានដំណើរការល្អដល់សព្វថ្ងៃ។ ប្រសិនបើគ្មានក្រុមណាមួយនោះ នោះសាលាបច្ចេកទេសដុនបូស្កូ ខេត្តព្រះសីហនុក៏គ្មានដែរ។

ឆ្លៀតឱកាសក្នុងពិធីបុណ្យកត្តញ្ញូនាថ្ងៃទី ២៤ ខែមិថុនា នេះយើងថ្លែងអំណរ គុណគ្នាទៅវិញទៅមក។ សូមព្រះជាម្ចាស់ប្រទានពរជ័យ ផ្តល់នូវអ្វីៗដែលល្អដូចជាភាពរួសរាយ រាក់ទាក់ និងសុខភាពល្អដោយស្ថិតនៅការថែរក្សាពីព្រះអង្គ។

សូមទទួលនូវការគោរពដ៏កក់ក្តៅពីខ្ញុំ

**លោកឪពុក ចន វីស៊ី**

អធិការសាលាដុន បូស្កូ ខេត្តព្រះសីហនុ

ក្រុមទីបីគឺជាអ្នកជំនួយដ៏ឧដុងឧត្តមរបស់យើង ដែលបានជួយឧបត្ថម្ភនៅទ្បព្រសម្បត្តិ និងគំនិតល្អៗ ដើម្បីអោយសាលាដុន បូស្កូមានដំណើរការល្អដល់សព្វថ្ងៃ។

ព្រឹត្តិប័ត្រសាឡេស៊ានជាភាសាខ្មែរត្រូវបានរកឃើញដោយផ្នែកទំនាក់ទំនងសង្គម នៃសាលាបច្ចេក ទេសដុនបូស្កូខេត្តព្រះសីហនុ ព្រះរាជាណាចក្រកម្ពុជា។

**ខ្ញុំចង់ចាំដំណើរទស្សនកិច្ច របស់អ្នកម្ដាយ អ៊ីវ៉ូនេ មកកាន់ប្រទេសកម្ពុជា**

អ្នកម្ដាយធំរបស់គ្រួសារសាឡេស៊ានស្រី បានមកទស្សនកិច្ចនៅប្រទេសកម្ពុជា កាលពីបួនខែមុន...!

**ដំនើរទស្សនកិច្ចនៅ ដុន បូស្កូ ប៉ោយប៉ែត**

មជ្ឈមណ្ឌល ដុន បូស្កូ ប៉ោយប៉ែត មើលទៅដូចជា...

**ឱកាសដើម្បីនិយាយថាអរគុណ**

ខែមិថុនាជាខែមួយដែលសិស្សានុសិស្សឆ្នាំពីរនៃសាលាបច្ចេកទេស និយាយពាក្យជំរាបលា ដល់ ដុន បូស្កូ

**អូលីវីយេ ផ្អិតហាស្សេ ជាអភិបាលថ្មីនៅ**

ដែលជាអភិបាលថ្មីជំនួសនៃបុព្វជិតរងនៅទីក្រុងភ្នំពេញ

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសប្បុរសជន**

ការងាររបស់ដុន បូស្កូក្នុងប្រទេសកម្ពុជាមានដំណើរការ យ៉ាងរលូនដោយសារការជួយឧបត្ថម្ភពីសំណាក់សប្បុរសជនជាច្រើន

**ព្រះវិហារព្រះនាងម៉ារី ហែប**

តើការផ្លាស់ប្ដូរព្រះវិហារថ្មីរបស់ដុន បូស្កូ ភ្នំពេញ មានលក្ខណៈ

គ្រួសារសាឡេស៊ានដុន បូស្កូ សំដែងការទទួលរាក់ទាក់ដល់អ្នកម្ដាយ អ៊ីវ៉ូនេ រៀងហ្គូត ជាអ្នកម្ដាយធំរបស់កូនស្រី ម៉ារីហែប នៅដុន បូស្កូ ទឹកថ្លា ភ្នំពេញ កាលពីថ្ងៃទី ១១ ខែកុម្ភៈ ឆ្នាំ ២០១០។ រូបភាពពីស្ដាំមកឆ្វេង: រូបទី១ លោកពុក រ៉ូអេល សូតូ (Fr. Roel Soto) រូបទីពីរ បងប្រុស រ៉ូប៊ឺតូ ផេនិតតូ (Br. Roberto Panetto) រូបទីបី អ្នកម្ដាយ អ៊ីវ៉ូនេ (Mother Yvonne) រូបទីបួន លោកពុក អាល់បេរ្តូ រ៉ូដាស់ (Fr. Al Rodas) និងរូបទីប្រាំ លោកពុក លេអូ អូឆូអា( Fr. Leo Ochoa.)



# ខ្ញុំចង់ចាំដំណើរទស្សនកិច្ច របស់អ្នកម្តាយ អ៊ីវ៉ូនេ មក កាន់ប្រទេសកម្ពុជា




*ដោយៈ លោកពុក អាល់បេរូ រូដាស់ និង លោក ហ្វាប្យេន បឺហ្កេវស មជ្ឈមណ្ឌលទំនាក់ទំនងសាឡេស៊ាន នៃប្រទេសកម្ពុជា ឆ្នាំ ២០១០*

ភ្នំពេញៈ កាលពីថ្ងៃទី ២៤ កុម្ភៈ ឆ្នាំ ២០១០ អ្នកម្តាយធំរបស់កូនស្រី គ្រួសារសាឡេស៊ាន គឺអ្នកម្តាយ **អ៊ីវ៉ូនេ រៀងហ្វូត** ថ្មីៗនេះបានមកទស្សនានៅប្រទេសកម្ពុជា ជាលើកដំបូង ហើយនេះក៏ជាពេលវេលាដ៏វិសេសវិសាលមួយ សំរាប់កូនស្រីៗ របស់គាត់ដែលមានបីសហគមន៍ នៅក្នុងប្រទេសកម្ពុជា គឺពីរសហគមន៍នៅទីក្រុងភ្នំពេញ ហើយមួយសហគមន៍ទៀតនៅ ខេត្តបាត់ដំបង ដែលស្ថិតនៅភាគខាងជើងនៃប្រទេសកម្ពុជា។ តាមពិតទៅពួកគាត់មានខ្លឹមសារយ៉ាងសំខាន់មួយនៅក្នុងប្រទេសកម្ពុជា ជាមួយកូនស្រីប្រមាណ១៧នាក់ ឬច្រើនជាងនេះហើយនៅទីក្រុងភ្នំពេញក៏មានកន្លែងស្នាក់ការ សំរាប់ កម្ពុជា និង មីយ៉ាន់ម៉ា។

**សយ័ណ្ហាសួរស្តី ! អ្នកម្តាយ អ៊ីវ៉ូននេ តើអ្នកម្តាយមានសារអ្វីខ្លះដែលអ្នកម្តាយយកមកជាមួយក្នុង ដំនើរទស្សនាក្នុងប្រទេសកម្ពុជា?**

ជាការពិតណាស់ មានសារនៃក្តីសង្ឃឹមមួយ ដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជា គឺវត្តមានមួយក្នុង វិស័យអប់រំ ហើយដែលបានធ្វើការ សម្រាប់វិស័យអប់រំ មានន័យថា "**ក្តីសង្ឃឹម** " ។ វាមានន័យថាៈ ធ្វើការដើម្បីស្អាបនាសំរាប់ថ្ងៃនេះ ក៏ដូចជាសំរាប់ថ្ងៃស្អែកផងដែរ ។ នៅក្នុងពិភពលោកពេលខ្លះក្តីសង្ឃឹមគឺមានភាពខ្សត់ខ្សោយ តែទោះបីជាយ៉ាងណាក៏ដោយវាគឺជាក្តីសប្បាយរីករាយសម្រាប់ខ្ញុំដើម្បីគាំទ្រដល់ប្រជាជនទាំងឡាយនៅក្នុងប្រទេសកម្ពុជា ដើម្បីភាពជឿជាក់ក្នុងពេលអនាគត ជាពិសេសតាមរយៈការអប់រំនៃពួកក្មេងៗ និងយុវជន។

**ជានិច្ចកាលយើងតែងតែលឺអំពីបញ្ហាខ្លះៗដែលកើតមានចំពោះស្ត្រីកម្ពុជាសព្វថ្ងៃនេះដូចជាៈ អំពើហិង្សាក្នុងគ្រួសារ ភាពហត់នឿយខ្លាំងក្នុងការងារ និងការធ្វើអាជីវកម្មផ្លូវភេទ។ តើអ្វីទៅដែលជាការឆ្លើយតបពីស្ត្រីទាំងឡាយនៃក្រុមគ្រួសារសាឡេស៊ានចំពោះស្ត្រីកម្ពុជា ?**



ក្រុមស្ត្រីសាឡេស៊ាន ព្យាយាមដោយក្តីរីករាយក្រៃលែងចំពោះស្ត្រីវ័យក្មេងកម្ពុជា ដែលមានបទពិសោធន៍ផ្ទាល់នៅក្នុងគ្រួសារ ហើយក៏ដូចជានៅក្នុងសង្គមយ៉ាងលំបាកនេះដែរ គឺដើម្បីផ្តល់លទ្ធភាពអោយពួកគាត់រស់នៅក្នុងភាពស្ងប់ស្ងាត់មួយ ហើយនិងនៅក្នុងបរិយាកាសមួយ ដ៏សមស្របរវាងម្តាយនិងកូន ។ ទីមួយគឺដើម្បីអោយស្ត្រីទទួលបានមកវិញ នូវថាមពលគ្រប់គ្រាន់ត្រៀមលក្ខណៈដើម្បីក្លាយជាស្ត្រីដ៏ល្អដែលយើងសង្ឃឹមនាពេលអនាគតកាល និង ដើម្បីអោយពួកគាត់មាន លទ្ធភាពគ្រប់គ្រាន់សម្រាប់គ្រួសារផ្ទាល់ខ្លួនរបស់ពួកគាត់ហើយ និង រកអោយបាននូវភាពជោគជ័យ ក្នុងជីវិតរបស់ពួកគាត់ ។ ចំនុចដទៃទៀតគឺការអភិវឌ្ឍន៍នៃការបង្កើតជំនាញវិជ្ជាជីវៈរបស់ពួកគាត់ ។ ជាការពិតគឺយើងផ្តល់អោយ ដូចជា ការផ្តល់នូវជំនាញផ្សេងៗចំពោះស្ត្រីវ័យក្មេង ដើម្បីអោយពួកគេ មានលទ្ធភាពធ្វើការងារ និងសន្សំប្រាក់កាសរបស់គាត់ផ្ទាល់ខ្លួន ដើម្បីរស់នៅក្នុងភាពថ្លៃថ្នូរ និង ដើម្បីមិនអោយមានការបៀតបៀនពីសំណាក់

អ្នកដទៃ និងខិតខំពង្រឹងគ្រួសាររបស់គាត់ ។ ពេលនោះផងដែរ គាត់ក៏បានទទួលនូវការបង្ហាត់បង្រៀនមួយនៃតម្លៃមនុស្ស និង តម្លៃផ្លូវចិត្ត ដូច្នេះគាត់នឹងរកឃើញអត្ថន័យក្នុងជីវិត ។ឆ្លងតាមការទទួលបាននូវព័ត៌មានគឺដោយមានការចុះទៅដល់គ្រួសារផ្ទាល់ពីសំនាក់ស្ត្រី ព្រោះថា ស្ត្រីជាចំណែកមួយដែលមានឥទ្ធិពលធំសំខាន់។ ទោះបីជាសង្គមមិនទទួលស្គាល់ពីភាពស្មើគ្នា ប៉ុន្តែជាការពិតដូចជាៈ សកម្មភាពផ្សេងៗនៅក្នុងសង្គមជាពិសេសគឺសកម្មភាពអប់រំដែលបានផ្តល់ អោយក្មេងៗ គឺពិតជាចំណែកមួយដែលមិនអាចខ្វះបាន។

**ប្រទេសមីយ៉ាន់ម៉ា និងប្រទេសកម្ពុជា ជាខេត្តដែលមានក្រុមគ្រួសារបងស្រីសាឡេស៊ាន។ ហេតុអ្វីបានជាអ្នកម្តាយជ្រើសរើសកម្ពុជាជាទីចាត់ការរបស់គ្រួសារបងស្រីសាឡេស៊ាន?** ការជ្រើសយកក្រុងភ្នំពេញជាទីតាំងធំគឺមានទំនាក់ទំនងជាមួយនិងការចាប់ផ្តើមនៃវត្តមាននៅ ក្នុងតំបន់នៃគ្រួសារសាឡេស៊ាន ប៉ុន្តែវាក៏អាចបង្កនូវភាពងាយស្រួលក្នុងការធ្វើការនៅក្នុងប្រទេស កម្ពុជាដែរ។ ឥឡូវនេះយើងកំពុង តែធ្វើការស្នើរសុំសំរាប់ការអភិវឌ្ឍន៍ដោយធ្វើការប្រតិបត្តិនូវ សកម្មភាពអប់រំដែលមានរយៈពេលច្រើនឆ្នាំ កាលដែលមានកន្លែងជាទីចាត់ការនៅទីនេះគឺជា



ដំណោះស្រាយមួយដែលសំខាន់នៅក្នុងហេតុផលនេះ។

**តើវិជ្ជាជីវៈអ្វីដែលជាក្តីសង្ឃឹមរបស់បងស្រីសាឡេស៊ាននៅអាស៊ី?** ក្តីសង្ឃឹមសំរាប់វិជ្ជាជីវៈនៅក្នុងអាស៊ីអាស្រ័យលើប្រទេសដែលមានជាប់ទាក់ទង។មានប្រទេសមួយចំនួនដែលមានការងារជាច្រើនសំរាប់សាឡេស៊ាន ដូចជាប្រទេសវៀតណាម ឥណ្ឌា ទីម័រខាងកើត ឥណ្ឌូណេស៊ី ភីលីពីន កូរេខាងត្បូង និងប្រទេសមីយ៉ាន់ម៉ា ប៉ុន្តែប្រទេសកម្ពុជាវិញ ពីព្រោះនៃប្រវត្តិសាស្ត្ររបស់វាដែលត្រូវការពេលវេលាបន្ថែម។ យើងមានបងស្រីសាឡេស៊ានដំបូងជាជនជាតិខ្មែរ ហើយនិងក្មេងស្រីជាច្រើនស្ថិតនៅក្នុងការ បង្កបង្កើត។ ដូច្នោះយើងសង្ឃឹមថាគ្រួសារសាឡេស៊ាននឹងមានការរីកចំរើនជាមួយនិងការជួយព្រំព្រេងរបស់បងស្រី ទើបពួកគេនឹងក្លាយជាអ្នកអប់រំដ៏ល្អទាំងវ័យក្មេង ។ ការសង្ឃឹមព្រមទាំងផ្តាច់ផ្តាចិត្តរបស់ធ្វើឲ្យបានល្អសំរាប់វិជ្ជាជីវៈនៅក្នុងអាស៊ីពីព្រោះយើងមានការជឿជាក់ថាសេចក្តីមេត្តាករុណារបស់ លោកឪពុកបូស្កូបានប្រមូលផ្តុំនូវកុមារនិងមនុស្សចាស់ជាច្រើនអោយឆ្លងកាត់វប្បធម៌អរិយធម៌នៅអាស៊ីទាំងអស់។ វាគឺជាការឆ្លាតវៃផងដែរពីព្រោះវាសន្មតថាយើងនឹងដើរតាមមាគ៌ាពួកគាត់ ហេតុដូច្នោះចិត្តករុណាគឺពិតជាបញ្ចូលទៅក្នុងវប្បធម៌ ។ **មាគ៌ានេះជាការងារដ៏ល្អសំរាប់យុវជនគួរយល់ដឹងឲ្យច្បាស់ពីជីវិតរបស់លោកឪពុកបូស្កូ នៅក្នុងឆាក់ ជីវិត របស់គាត់**គ្រួសារសាឡេសានបានចាប់ផ្តើមនៅថ្ងៃទី ៣១ ខែមករា ដូចដែលយើងធ្លាប់បាននិយាយថា លោក**ឪពុក ដុន បូស្កូ** បានលាចាក់លោកនេះទៅកាន់លោកខាងមុខហើយ។ លោកគឺជាមនុស្សម្នាក់ដែលមានភាពល្បីល្បាញ នៅក្នុងសតវត្សរ៍ទី១៩ ហើយលោកបានបន្សល់ទុកនៅស្លាក់ស្នាមស្នាដៃល្អៗជាច្រើនរហូតមកដល់បច្ចុប្បន្ននេះ។

# ដំណើរទស្សនកិច្ចដុន បូស្កូប៉ោយប៉ែត



Automotive section of Don Bosco Poipet.

ដោយៈ អ៊ិច សំបូរ

ការយល់ដឹងពី សាឡេស៊ានប៉ោយប៉ែត គឺជាបទពិសោធន៍មួយដ៏អស្ចារ្យបំផុត។ ខ្ញុំបាទបានធ្វើដំណើរចេញពីក្រុងព្រះសីហានុដើម្បីទៅព្រំដែនប៉ោយប៉ែតនៅថ្ងៃ អង្គារទី៣ ខែមិថុនាជាមួយនិង លោក ហាន សុរិ ដែលជាសិស្សរៀនផ្នែកទំនាក់ទំនងសង្គម។ ហើយក្នុងការធ្វើដំណើរពួកយើងបានជិះឡានក្រុងចេញពីក្រុងព្រះសីហានុទាំងយប់ទៅ ដល់ទីរួមខេត្តសៀមរាប នៅម៉ោង៥ និង៣០នាទីព្រឹក ។ ហើយបានធ្វើដំណើរអស់រយៈពេល ២ម៉ោង និង២០ នាទីទៀត ពីក្រុងសៀមរាបរហូតដល់ច្រកឆ្លងទ្វាទល់ដែនថៃ។ លោកឪពុក ហ្គាប្រីអែល ខេង និង លោកពុក អូជិនេ សាលស្ស បានទទួលស្វាគមន៍ពួកយើងយ៉ាងកក់ក្តៅ។ លោកឪពុក ហ្គាប្រីអែល ខេង ជាគ្រូសារសាឡេស៊ាន ជនជាតិកូរ៉េ និងជាអធិការសាលា ចំនែកឯលោក ឪពុកយ៉ុងចឺន ជាអធិការរងសាលា គាត់ទាំងពីរមានចិត្តល្អចំពោះពួកយើងខ្លាំងណាស់។ ជាមួយគ្នានេះដែរពួកយើងបាន ដើរមើលអាគារជាច្រើនកន្លែងខុសៗគ្នាក្នុងបរិវេនសាលា ព្រមទាំងបានចែករំលែកបទពិសោធន៍ខ្លះៗជាមួយសិស្សចែករំលែកបទពិសោធន៍ខ្លះៗជាមួយសិស្សស្នាក់ក្នុង និង លោកគ្រូ អ្នកគ្រូមួយចំនួន។ ដុន បូស្កូប៉ោយប៉ែតក៏មានសាលាអន្តេវាសិកសំរាប់បង្រៀនដល់ក្មេងៗដូចសាលារង្វែរ ពីព្រោះក្មេងៗនៅប៉ោយប៉ែតភាគច្រើនត្រូវបានគេបញ្ជូនទៅធ្វើការ ដូច្នោះការដាស់តឿនអោយពួកគេខិតខំរៀន គឺជាការងារមួយដ៏សំខាន់សំរាប់ដុន បូស្កូ ។

ក្នុងនោះក៏មានក្មេងប្រុស ស្រីមួយចំនួនបានកំពុងរស់នៅក្នុងសាលាផងដែរ ដែលពួកគេជាក្មេងដែលត្រូវបានគេបោះបង់ចោលក្មេងកំព្រា ក្មេងរងគ្រោះដោយអំពើជួញដូរមនុស្សនៅប្រទេសថៃ។ ក្មេងៗទាំងនោះមានភាពរាក់ទាក់ជាមួយពួកយើងយ៉ាងខ្លាំងហើយពួកគេបានសួរសំនួរជាច្រើនប្រៀបបីដូចជាអ្នកកាយការណ៍ដ៏ជំនាញ។ មជ្ឈមណ្ឌលដុន បូស្កូប៉ោយប៉ែតមានផ្នែកបច្ចេកទេសពីរគឺ ផ្នែកយន្តសាស្ត្ររថយន្ត និង ផ្នែកអគ្គិសនី ដែលមានលក្ខណៈខុសគ្នាពីសាលាដុន បូស្កូ ខេត្តព្រះសីហានុនិងក្រុងភ្នំពេញ ចំនែកឯសិស្សវិញគឺមិនរៀនពេញមួយថ្ងៃទេ តែគេបែងចែកជាពីរក្រុមគឺ ក្រុមពេលព្រឹកនិងពេលរសៀល។ មូលហេតុដែលពួកគេបែងចែកដូចនេះដោយសារ




**www.donboscopoipet02.org**



[illegible]តក្មេងភាគច្រើននៅប៉ោយប៉ែតជា អ្នកធ្វើការហើយនេះជាវិធី តែមួយដែលអាចអោយពួកគេមកសាលារៀនបាន។ ទោះបីជាយ៉ាងណា ក៏នៅមានសិស្សដែលមកពីបណ្តាខេត្តឆ្ងាយៗកំពុងស្នាក់នៅក្នុងសាលាដែរ។ លើសពីនេះទៅទៀតពួកយើងក៏បានស្គាល់កាស៊ីនូល្បីៗនៅជាប់ព្រំដែនដែលមានសម្រស់ស្រស់ស្អាត និងសំបូរដោយអ្នកមានលុយចូលទៅលេងនូវទីនោះ ស្របពេលដែលក្រុងប៉ោយប៉ែតកំពុងតែជួបភាពក្រីក្រ។ សាលាដុនបូស្កូ បានកំពុងធ្វើការយ៉ាងល្អពិតប្រាកដសំរាប់ជួយដល់ក្មេងៗ ក៏ដូចជាជួយអភិវឌ្ឍន៍ សង្គមជាតិ។


Living in Don Bosco Children Home Poipet.

# ឱកាសដើម្បីនិយាយថាអរគុណ



ជារៀងរាល់ខែមិថុនា គ្រប់សាលាសាឡេស៊ាន នៅក្នុងប្រទេសកម្ពុជា ជាពេលវេលាមួយដែលមានការមមាញឹកសំរាប់មនុស្សគ្រប់គ្នា។ប៉ុន្តែវាជាឱកាសមួយដ៏ពិសេសសំរាប់សិស្សឆ្នាំទី២។ពួកគេមានការព្រួយបារម្ភក្នុងការរៀបចំទំរង់បែបបទដើម្បីស្វែងរកនៅការងារធ្វើ និងត្រៀមខ្លួនសំរាប់ឆមាសចុងក្រោយរបស់ពួកគេ ព្រមទាំងនិយាយពាក្យលាលាពីផុន បូស្កូ។ហើយក៏មានថ្ងៃប្រារព្ធពិធីអគុណ ដែលផ្តល់ឱកាសអោយសិស្សឆ្នាំទី២សងគុណទៅដល់គ្រូបាអាចារ្យ របស់ពួកគេ និងធ្វើការនឹករលឹកក៏ដូចជាគោរពដឹងគុណចំពោះសាលា។ ពួកគេបានចំនាយពេលវេលាដ៏មានតំលៃដើម្បីរៀបចំ ការសមបទចំរៀង រាំ សំដែងល្ខោន ក៏ដូចជាថ្លាថ្លែងនៅពាក្យអរគុណ ទៅដល់ "លោកឪពុកបូស្កូ ដែលបានផ្តល់ឱកាសអោយពួកយើងទាំងអស់គ្នាបានមករៀននៅទីនេះ និង បានទទួលនៅអាជីពមួយសំរាប់ចិញ្ចឹមជីវិតទីថ្ងៃអនាគត់ "។ហើយនៅថ្ងៃដ៏ឧឡារិកនោះផងដែរ ក៏មានអតីតសិស្សចាស់ មកទស្សនា និង ពោលពាក្យអគុណសាជាថ្មីម្តងហើយម្តងទៀត។

នៅក្នុងនោះសំរាប់ដួងព្រលឹងបងប្អូនសាឡេស៊ានរបស់លោកឪពុកបូស្កូ ការដឹងគុណគឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងការបង្ហាញពីទឹកចិត្តរបស់ពួកយើង។យើងទាំងអស់គ្នាគួរតែនិយាយដូចទៅនឹងចំរៀង របស់ អែលថុន ចន និង បែកស្ទីតបយ ដែលច្រៀងឡើងថា: " មិត្តភក្តិមិនដែលនិយាយថាលាហើយទេ "។

គ្មានអ្វីដែលខ្ញុំមិនបានចែករំលែកក្នុងមាគារជាមួយ
អ្នកនោះទេហើយអ្វីៗទាំងអស់វាតែងតែស្ថិតនៅ
ឯរៀងរាវបន្ទាប់និងកើតឡើង នៅថ្ងៃស្អែក
ភ្លាមៗនោះវាមិនពិតឡើយវាមាននៅ
ផ្លូវដ៏ទៃផ្សេងទៀតបែកគ្នាដោយ
ការបោយដៃលាចង់សួរតែពិ
បាកនិយាយអ្នកណានិ
យាយថាអ្នកខុសរឺត្រូវ
ផ្លូវរបស់នរណាអ្នក
នោះជាអ្នករត់ដោយ
អង់អាចរហូតដល់ពេល
យើងមានជំហរនិងក្លាយទៅ
ជាមនុស្សម្នាក់ដ៏ប្រពៃតើអ្វីទៅ
ដែលត្រូវធ្វើអោយល្អបំផុតទោះជា
ហូរទឹកភ្នែកក៏នៅតែព្យាយាមដែលទឹក
ភ្នែកនោះវាគ្រាន់តែជាភាពច្របូកច្របល់
នៅអ្វីដែលខ្ញុំបាត់បង់ប៉ុន្តែបើខ្ញុំចាប់ផ្តើមបន្ថែម
ទៀតខ្ញុំអាចមានដំណើរស្របគ្នាជាមួយនិងភាពសប្បាយ
និងភាពសោកសៅនៅក្នុងមាគារនីមួយៗភាពរំភើបរបស់
ខ្ញុំនិងបង្រៀនខ្ញុំថាមិត្តភក្តិរបស់ខ្ញុំមិនដែនិយាយមិនដែលនិយាយ
ថាលាហើយមិនដែលនិយាយថាលាហើយមិដែលនិយាយថាលា
ហើយមិនដែលនិយាយថាលាហើយភ្លាមៗនោះវាមិនពិតឡើយ
វាមាននៅផ្លូវដ៏ទៃផ្សេងទៀតបែកគ្នាដោយការបោយដៃលាខ្ញុំ
គួរតែមានដំណើរស្របគ្នាជាមួយនិងភាពសប្បាយនិងភាព
សោកសៅនៅក្នុងមាគារនីមួយៗភាពរំភើបរបស់ខ្ញុំនិង
បង្រៀនខ្ញុំថាមិត្តភក្តិរបស់ខ្ញុំមិនដែលនិយាយមិន
ដែលនិយាយថាលាហើយមិនដែលនិយាយ
ថាលាហើយមិនដែលនិយាយថាលា
ហើយមិនដែលនិយាយថាលា
**ហើយមិត្តភក្តិរបស់ខ្ញុំមិនដែលនិ**
**យាយមិនដែលនិយាយថាលាហើយ**

# អូលីវីយេ៉ ផ្មិតហស្លេរ ជាអភិបាលថ្មីនៅភូមិភាគភ្នំពេញ



លោក អូលីវីយេ៉ ផ្មិតហស្លេរ ត្រូវបានបំបួសជាអភិបាលរងជំនួសលោកអភិបាល នៅភូមិភាគ ភ្នំពេញ កាលពីថ្ងៃទី២០ ខែមីនា ឆ្នាំ ២០១០ នៅព្រះវិហារម៉ារីហែប ផុនបូស្វភ្នំពេញ ដោយលោកប្រធាន សាលវេថើ ផេននាឈីអូ អេបស្វូលីក ញូសុីអូ។ លោកអភិបាលដែលទើបតែងតាំងថ្មីនៅកម្ពុជា ជាអ្នកជួយដល់លោកអភិបាលប្រធាន អេមីល ដេតម្ប។ "សេចក្តីស្រលាញ់ដែលព្រះគ្រីស្តផ្តល់អោយយើង" ដែលជាបាវចនារបស់គាត់ក្នុងនាម លោកអភិបាលកើត នៅ ស្ត្រាសប៊ួ ទីក្រុងភាគខាងជើងនៃប្រទេសបារាំង ក្បែរព្រំប្រទល់ ប្រទេស អាល្លឺមង់ក្នុងឆ្នាំ១៩៧០។ គាត់បានមកប្រទេសកម្ពុជាក្នុងនាមជាបូជាចារ្យនៃបេសកម្មសាសនាទូតក្រុងប៉ារីសនៅ ឆ្នាំ១៩៩៨ ដែលជាសេចក្តីត្រូវការជំចាំបាច់ចំពោះក្មេងៗ និង យុវជន ។

លោកប្រធាន អូលីវីយេ៉ បានកសាងអាគារនិងសាលាជាច្រើនក្នុងបេសកម្មជាបូជាចារ្យនាឆ្នាំដំបូងរបស់គាត់ ហើយគាត់បានបង្កើតរឿងរ៉ាវបន្ថែមដែលពោរពេញដោយអត្ថន័យនៅក្នុងខេត្តតាកែវ។ វាពិតជាមានភាពរីករាយយ៉ាងក្រៃលែងសំរាប់ព្រះវិហារកាតូលិកនៅកម្ពុជា ព្រមទាំង គ្រួសារសាឡេស៊ាននៅលើការអនុម័តរបស់គាត់ហើយគាត់ក៏បានទទួលកិត្តិយស និងភាពទទួលខុសត្រូវនៅព្រះវិហារសាឡេស៊ាន។ នៅក្នុងរូបភាពនេះ លោកអភិបាល អូលីវីយេ៉ នៅចន្លោះ លោកប្រធាន អេមីល ដេតម្ប និងអ្នកម្តាយ **អ៊ីរ៉េន** ដែលជាបងស្រីធំសាឡេស៊ានគ្រប់គ្រងផ្នែកទូទៅក្នុងពេលជួបគ្នា របស់គាត់នៅប្រទេស កម្ពុជាកាលពីដើមខែកុម្ភៈ។



# សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

# សប្បុរសជន



អ្វីៗដែលបាន ចាប់ផ្តើមនេះ គឺក្លាយមកពីអ្វីៗ ដែលបានកើតឡើងក្នុងជំរុំខ្មែរ ភៀសខ្លួននៅក្នុងប្រទេសថៃ ។ នៅក្នុងរូបភាពឆ្នាំ ១៩៨២ លោក ឪពុក បាទីសថា ធីសាន់ និនី នជាមួយក្មេងជនភៀសខ្លួន ។ បីទសវត្សរ៍ក្រោយមក សាលាដុនបូស្កូបន្តជួយកុមារ និង យុវជនកម្ពុជា ចេញពីភាពក្រីក្រ ។ ពួកយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះព្រះជាម្ចាស់ និង សប្បុរសជនដែលអោយ អ្វីៗមាន ដំណើរការរហូតមក។អ្វីដែលយើងសំរេចគឺបូជាជីវិតយើងផ្ទាល់ ដើម្បីគង់នៅជាមួយយើងទាំងអស់គ្នា ជីវិតអស់កល្បជានិច្ចនៅ ក្នុងពិភពលោកយើងនេះ។

## ព្រះវិហារសន្តីម៉ារីហែប ក្រុងភ្នំពេញ



យេវ៉្សីចាំថានៅក្នុងឆ្នាំនេះ នៅខែ ឧសភា ព្រះវិហារចាស់របស់សាលាបច្ចេកទេសដុនបូស្កូភ្នំពេញ បានកសាងថ្មីក្រោមការជួយឧបត្ថម្ភរបស់សាសនិកព្រះវិហារម៉ារីហែប។ គំរោងនេះត្រូវបានដឹកនាំផ្ទួច ផ្តេម៉្សឺឡង់ម៉្សឺដោយលោកឪពុក លេអូ អូឡេឌាំ អធិការសាលាដុនបូស្កូភ្នំពេញ។ព្រះវិហារបានកសាងនៅឆ្នាំ ១៩៩១ក្រោមមូលនិធិរបស់សាលាដុនបូស្កូ និងការជួយពីក្រុមគ្រួសារសាឡេស៊ាន កម្ពុជា ក្នុងដំណើរទស្សនៈកិច្ចរបស់លោកឪពុក ដុន បេកគី ដែលជាប្រធានធំរបស់គ្រួសារសាឡេស៊ានក្នុងឆ្នាំ ១៩៩៧។ នៅខែ មីនា ឆ្នាំ ២០១០ នេះ លោកអភិបាលអូលីវីយេស្មិតហាស្លេរ ត្រូវបានតែងតាំង ជាលោកអភិបាលថ្មី នៅភ្នំពេញពីគ្រីស្ត ទុតណានសីអូ ដោយលោកអភិបាលសាលវ៉ាឌ័រ ភេនាឈីអូ។

នៅក្នុងព្រះវិហារក៏មានតាំងរូបសំណាក់លោកអធិការបូជាចារ្យ ព្រមទាំងមានសេវ៉្សៅអប់រំអំពីឡេឆា សំខាន់ៗនៃគ្រីស្តសាសនា ក៏ដូចជាវិធីណែនាំគ្រីស្តបរិស័ទ។



# សាលាបច្ចេកទេសដុន
# បូស្កូ ខេត្តព្រះសីហនុ



ស្ទូឌីយោ, ផលិតសម្លេង វីដេអូ
និង មានជួលបន្ទប់ស្ទូឌីយោ
ព្រមទាំងមានសេវាកម្មទទួល
បង្កើតគេហទំព័រ ក្នុងតំលៃថោក
សមរម្យ




សូមទំនាក់ទំនង:

(៨៥៥) ៩៧ ៩៧៦ ៥០៤២

(៨៥៥) ១៦ ៥២ ៤២ ៤១

អ៊ីម៉ែល:management@donboscosihanoukville.org

www.donboscosihanoukville.org